## សេចក្ដីប្រកាសព័ត៌មាន

ទីក្រុងឡុងប៊ិច
ការិយាល័យព័ត៌មានសាធារណៈ
៤១១ W. Ocean Blvd,
ឡុងប៊ិច, កាលីហ្វ័រញ៉ា ៩០៨០២

**៤/៦/២០២០**

សម្រាប់សេចក្ដីប្រកាសបន្ទាន់ សេចក្ដីប្រកាសព័ត៌មាន លេខ ០៤០៦២០

**ប្រធានបទ៖ ទីក្រុងឡុងប៊ិចបានបើកគ្លីនិកធ្វើរោគវិនិច្ឆ័យរហ័សនិងកន្លែងធ្វើតេស្តថ្មីដែលមិនតម្រូវឱ្យចេញពីឡាន**

**ទំនាក់ទំនង៖** មជ្ឈមណ្ឌលព័ត៌មានរួមទីក្រុងឡុងប៊ិច
៥៦២.៥៧០.NEWS (សម្រាប់ទទួលសំណួរពីអ្នកសារព័ត៌មានតែប៉ុណ្ណោះ)
jic@longbeach.gov (សម្រាប់ទទួលសំណួរពីអ្នកសារព័ត៌មានតែប៉ុណ្ណោះ)
សាធារណៈជន៖សូមទូរស័ព្ទមកលេខ ៥៦២.៥៧០.INFO



ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា-ថ្ងៃនេះទីក្រុងឡុងប៊ិចបានបើកគ្លីនិកធ្វើរោគវិនិច្ឆ័យរហ័សដើម្បីផ្ដល់ជំនួយផ្នែកវេជ្ជសាស្ត្រដល់ប្រជាជនដែលមានតម្រូវការទៅបន្ទប់សង្គ្រោះបន្ទាន់ដើម្បីទទួលការព្យាបាលជំងឺរបស់ពួកគាត់។

លោកអភិបាលក្រុងរ៉ូប៊ីតហ្គាសៀមានប្រសាសន៍ថា "គ្លីនិកធ្វើរោគវិនិច្ឆ័យរហ័សថ្មីនេះនឹងបម្រើសហគមន៍របស់យើងនិងបង្កើនកន្លែងទំនេរនៅក្នុងបន្ទប់សង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ។ លោកអ្នកដែលត្រូវការការព្យាបាលដោយឥតគិតថ្លៃអាចទទួលបានយ៉ាងរហ័សនិងដោយសុវត្ថិភាព។"

គ្លីនិកឥតគិតថ្លៃនេះមានទីតាំងនៅសាកលវិទ្យាល័យទីក្រុងឡុងប៊ិចសាខាប៉ាស៊ីហ្វិកខូស។ម៉ោងប្រតិបត្តិការគឺចាប់ពីម៉ោង ១០:០០ ព្រឹក ដល់ម៉ោង ៦:០០ ល្ងាច ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ចាប់ពីពេលនេះរហូតដល់មានការជូនដំណឹងបន្ថែម។

គ្លីនិកធ្វើរោគវិនិច្ឆ័យរហ័សអាចទទួលលោកអ្នកដែល **មិនមាន** រោគសញ្ញាជំងឺគ្រុនផ្តាសាយ។ លោកអ្នកអាចមកដោយមិនចាំបាច់ណាត់ជួបជាមុន។ អ្នកជំងឺអាចទទួលការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលជំងឺទូទៅដូចជាឈឺត្រចៀកនិងជំងឺរលាកតម្រងនោម។ លោកអ្នកក៏អាចស្នើសុំសំបុត្រទិញថ្នាំនិងបន្តវេជ្ជបញ្ជាសម្រាប់ថ្នាំទូទៅដូចជាថ្នាំគ្រាប់សម្រាប់ពន្យាកំណើតនិងថ្នាំសម្រាប់ជំងឺលើសឈាម ជំងឺក្រពះ (GERD) បញ្ហាដែលទាក់ទងនឹងក្រពេញទីរ៉ូអ៊ីត កូលេស្តេរ៉ុល ជំងឺទឹកនោមផ្អែម ជំងឺធ្លាក់ទឹកចិត្ត និងជំងឺប្រតិកម្មនឹងធាតុអ្វីមួយ។ ចំពោះលោកអ្នកដែលត្រូវការបន្តវេជ្ជបញ្ជាសម្រាប់ថ្នាំដែលអស់សូមយកបញ្ជីថ្នាំនិងកំរិតប្រើឬដបថ្នាំមកជាមួយប្រសិនបើមាន។

លោកអ្នកដែលមកដល់ហើយមានរោគសញ្ញាជំងឺគ្រុនផ្តាសាយក្នុងកម្រិតមធ្យមដែលរួមមាន ក្អក និងគ្រុនក្តៅដោយមិនមានកន្ទួលឬឈឺបំពង់ក នឹងត្រូវបានទទួលការធ្វើរោគវិនិច្ឆ័យនៅនឹងកន្លែង។ អ្នកជំងឺទាំងនេះនឹងចាកចេញពីគ្លីនិកព្រមជាមួយនឹងផែនការថែទាំអ្នកជំងឺបន្ត។

គ្លីនិកនឹងមិនធ្វើការថតដោយប្រើកាំរស្មីអ៊ិចឬបំពេញវេជ្ជបញ្ជានៅនឹងកន្លែងទេ។

ចាប់ពីថ្ងៃអង្គារទី ៧ ខែមេសា នឹងមានផ្តល់សេវាកម្មសម្រាប់លោកអ្នកដែលត្រូវការធ្វើតេស្តរកជំងឺកូវីដ-១៩ (COVID-19) នៅឯទីតាំងជិតគ្លីនិកធ្វើរោគវិនិច្ឆ័យរហ័សដែលតម្រូវឱ្យមានការណាត់ជួបជាមុនប៉ុន្តែមិនចាំបាច់ចេញពីឡាន។ លោកអ្នកដែលចាប់អារម្មណ៍សូមចូលទៅ ទំព័រតេស្តកូវីដ-១៩ នៃគេហទំព័ររបស់ទីក្រុង ហើយឆ្លើយសំណួរមួយចំនួន។ សម្រាប់បុគ្គលដែលមានរោគសញ្ញាកូវីដ-១៩ លោកអ្នកដែលមានបញ្ហាសុខភាព ឬ មានអាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ នឹងបានត្រូវផ្តល់អាទិភាពក្នុងការធ្វើតេស្ត។ ទីក្រុងរំពឹងថានឹងធ្វើតេស្តមនុស្សប្រមាណជា ១០០ នាក់ក្នុងមួយថ្ងៃ។

លទ្ធផលតេស្ត៍ត្រូវការពេលដំណើរការប្រមាណជា ៤៨ ម៉ោង។ អ្នកស៊ើបអង្កេតករណីនៅមន្ទីរសុខាភិបាលឡុងប៊ិចនឹងទូរស័ព្ទទៅបុគ្គលដែលលទ្ធផលតេស្តវិជ្ជមាន។ បុគ្គលដែលលទ្ធផលតេស្តអវិជ្ជមាននឹងត្រូវជូនដំណឹងដោយសំបុត្រតាមរយៈសេវាប្រៃសណីយ៍សហរដ្ឋអាមេរិក (United States Postal Service)។

នាយកគ្រប់គ្រងកម្មវិធីគ្រោះអាសន្នផ្នែកសុខភាពសាធារណៈលោកស្រី Sandy Wedgeworth បានមានប្រសាសន៍ថា "ការបើកគ្លីនិកធ្វើរោគវិនិច្ឆ័យរហ័សនៅថ្ងៃនេះគឺទទួលបានជោគជ័យដ៏ធំមួយ។ ក្នុងរយៈពេលពីរបីម៉ោងដំបូងពលរដ្ឋប្រមាណជា ៥០ នាក់បានទទួលការធ្វើរោគវិនិច្ឆ័យហើយភាគច្រើនក៏ត្រូវបានបញ្ជូនទៅធ្វើតេស្តរកជំងឺកូវីដ-១៩បន្ត។ ពេលវេលាមធ្យមភាគដែលអ្នកជំងឺចំណាយក្នុងតង់គឺ ១០ នាទីដូច្នេះយើងពិតជាគោរពតាមពាក្យសន្យារអំពីការផ្តល់ការព្យាបាលដែលសមរម្យនិងឆាប់រហ័ស។

ចំណតរថយន្តឥតគិតថ្លៃគឺមាននៅចំណតរថយន្តនៃមហាវិទ្យាល័យនៅជិតផ្លូវ Orange Avenue ខាងជើងនៃមហាវិថីប៉ាស៊ីហ្វិកខូស (Pacific Coast Highway)។ ផ្លាកសញ្ញានិងបុគ្គលិកនឹងជួយប្រាប់ផ្លូវដើម្បីជួយអ្នកជំងឺឱ្យទៅដល់ទីតាំង។

គ្លីនិកនេះមានបុគ្គលិកដែលជាសមាជិកនៃការិយាល័យបំរុងវេជ្ជសាស្ត្រទីក្រុងឡុងប៊ិចដែលមានទាំងអ្នកស្ម័គ្រចិត្តដែលមិនជំនាញវេជ្ជពេទ្យនិងអ្នកស្ម័គ្រចិត្តដែលជំនាញវេជ្ជពេទ្យមកពីសហគមន៍ រួមទាំងអ្នកជំនាញសុខភាពសាធារណៈ គ្រូពេទ្យ គិលានុបដ្ឋាយិកា អ្នកជំនួយពេទ្យ និងគិលានុបដ្ឋាយិកាជំនាញផងដែរ។ លោកអ្នកដែលចាប់អារម្មណ៍ក្នុងការស្ម័គ្រចិត្តសូមចូលទៅកាន់ គេហទំព័រ longbeach.gov/MRC។

សម្រាប់ព័ត៌មានថ្មីៗអំពីកូវីដ-១៩នឹងព័ត៌មានលំអិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជន សូមចូលទៅកាន់គេហទំព័រ៖ longbeach.gov/COVID19 និងតាមដាន @LongBeachCity នៅលើហ្វេសប៊ុក ធ្វីតធ័រ និង Instagram ។

សម្រាប់ព័ត៌មានបន្ថែម រូបភាព វីដេអូ និងសេចក្តីប្រកាសអំពីអ្វីដែលកំពុងកើតឡើងនៅឡុងប៊ិចសូម តាមដានទីក្រុងឡុងប៊ិចកនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។